This VIS translation is out of date. When you give your patient this translation, also give them the up-to-date English version of it. To get both, and to find out what was updated, go to www.immunize.org/vis

## សេចក្តីថ្លែងការណ៍ព័ត៌មានថ្នាំបង្ការ

# ថ្នាំបង្ការទីមួយរបស់កូនអ្នក

*អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍ព័ត៌មានថ្នាំបង្ការជាច្រើនមានជាភាសាអេស្ប៉ាញ និងភាសាផ្សេងទៀត ។ មើលគេហទំព័រ www.immunize.org/vis

កូនរបស់អ្នកនឹងទទួលបានថ្នាំបង្ការទាំងនេះនៅថ្ងៃនេះ ៖

☐ DTaP ☐ រោគខួរឆ្អឹងខ្នង
☐ Hib ☐ PCV13
☐ ជំងឺរលាកថ្លើមប្រភេទ B

*(អ្នកផ្តល់សេវាកម្ម ៖ គូសប្រអប់ដែលសមរម្យ ។)*

## 1 តើហេតុអ្វីត្រូវទទួលថ្នាំបង្ការ?

ថ្នាំបង្ការទាំងនេះអាចការពារកូនរបស់អ្នកពីជម្ងឺកុមារ ទាំង 7 មុខ ៖

**1. រោគខាន់ស្លាក់**
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងមានស្រទាប់ក្រាស់នៅខាងក្រោយបំពង់កដែលធ្វើឲ្យពិបាកដកដង្ហើម ។

**រោគខាន់ស្លាក់អាចបណ្តាលឲ្យមាន**បញ្ហាដកដង្ហើម ភាពខ្វិន និងបេះដូងចុះខ្សោយ ។

- មនុស្សប្រហែល 15,000 នាក់បានស្លាប់ជារៀងរាល់ឆ្នាំនៅក្នុងសហរដ្ឋអាមេរិកដោយសាររោគខាន់ស្លាក់មុនមានថ្នាំបង្ការ ។

**2. តេតាណូស** (**រឹងថ្គាម**)
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងការឈឺចាប់តឹងសាច់ដុំជាធម្មតាពេញរាងកាយ ។

**តេតាណូសអាចបណ្តាលឲ្យមាន**ភាពរឹងថ្គាមដែលធ្វើឲ្យពិបាកបើកមាត់ ឬលេប ។

- តេតាណូសសម្លាប់មនុស្សម្នាក់ក្នុងចំណោម 5 នាក់ដែលកើតវា ។

**3. ជំងឺក្អកមាន់** (**ក្អកមួយ**)
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងរយៈពេលការក្អកខ្លាំងដែលធ្វើឲ្យទារកពិបាកញ៉ាំ ផឹក ឬដកដង្ហើម ។ រយៈពេលទាំងនេះអាចយូរដល់រាប់សប្តាហ៍ ។

**ជំងឺក្អកមាន់អាចបណ្តាលឲ្យមាន**ជំងឺរលាកសួត ប្រកាច់ ខូចខួរក្បាល ឬស្លាប់ ។

**4.** Hib (**បាក់តេរីដែលបង្កឲ្យរលាកស្រោមខួរ**)
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងក្តៅខ្លួន ឈឺក្បាល រឹងក ក្អក និងដង្ហើមខ្លីៗ ។ អាចមិនមានសញ្ញា ឬលក្ខណៈរោគក្នុងករណីមធ្យម ។

Hib **អាចបណ្តាលឲ្យមាន**រោគរលាកស្រោមខួរ (ការឆ្លងមេរោគនៃខួរក្បាល និងគំរបខួរឆ្អឹងខ្នង) ជំងឺរលាកសួត ការឆ្លងមេរោគឈាម សន្លាក់ ឆ្អឹង និងគំរបបេះដូង ខូចខួរក្បាល និងថ្លង់ ។

- មុនមានថ្នាំបង្ការ ជម្ងឺ Hib ជាមូលហេតុចម្បងនៃមេរោគរលាកស្រោមខួរក្នុងកុមារអាយុក្រោម 5 ឆ្នាំនៅក្នុងសហរដ្ឋអាមេរិក ។

**5. ជំងឺរលាកថ្លើមប្រភេទ** B
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងភាពហត់នឿយ រាគរូសនិងក្អួត ជំងឺខាន់លឿង (ស្បែក ឬភ្នែកឡើងពណ៌លឿង) និងឈឺសាច់ដុំ សន្លាក់ និងក្រពះ ។ ប៉ុន្តែជាធម្មតាមិនមានសញ្ញា និងលក្ខណៈ
រោគអ្វីទាំងអស់ ។

**ជំងឺរលាកថ្លើមប្រភេទ** B **អាចបណ្តាលឲ្យមាន**ការខូចខាតថ្លើម និងមហារីកថ្លើម ។ អ្នកខ្លះកើតការឆ្លងមេរោគរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ (រយៈពេលយូរ) ។ អ្នកទាំងនេះអាចមើលទៅ ឬគ្មានអារម្មណ៍ឈឺ ប៉ុន្តែ ពួកគេអាចចម្លងអ្នកដទៃ ។

- ជំងឺរលាកថ្លើមប្រភេទ B អាចបង្ការឲ្យមានការខូចខាតថ្លើម និងមហារីកថ្លើមក្នុងចំណោមកុមារម្នាក់ នៃកុមារ 4 នាក់ដែលឆ្លងរ៉ាំរ៉ៃ ។

**6. រោគខួរឆ្អឹងខ្នង**
**សញ្ញា និងលក្ខណៈរោគ**នានាអាចរួមមានជម្ងឺដូចជាជម្ងឺផ្តាសាយ ឬអាចមិនមានសញ្ញា ឬលក្ខណៈរោគអ្វីទាល់តែសោះ។

**រោគខួរឆ្អឹងខ្នងអាចបណ្តាលឲ្យមាន**ភាពខ្វិនជាអចិន្ត្រៃយ៍ (មិនអាចប្រើដៃ ឬជើង ឬពេលខ្លះមិនអាចដកដង្ហើម) និងស្លាប់ ។

- នៅទសវត្សឆ្នាំ 1950 រោគខួរឆ្អឹងខ្នងបានធ្វើឲ្យមនុស្សខ្វិនលើសពី 15,000 នាក់ជារៀងរាល់ឆ្នាំនៅក្នុងសហរដ្ឋអាមេរិក ។

**7. ជម្ងឺ** Pneumococcal
**សញ្ញា និងលក្ខណៈរោគ**រាប់បញ្ចូលទាំងក្តៅខ្លួន ញ័រងា ក្អក និងឈឺដើមទ្រូង ។

**ជម្ងឺ** Pneumococcal **អាចបណ្តាលឲ្យមាន**រោគរលាកស្រោមខួរ (ការឆ្លងមេរោគនៃខួរក្បាល និងគំរបខួរឆ្អឹងខ្នង) ការឆ្លងមេរោគឈាម ការឆ្លងមេរោគត្រចៀក ជំងឺរលាកសួត ថ្លង់ និងការខូចខួរក្បាល ។ ជម្ងឺទាំងនេះមិនសូវមានច្រើនដូចពីមុនទេ ។ ប៉ុន្តែមេរោគបង្កនៅតែមាន ហើយទោះបីជាជម្ងឺដែលស្ទើរតែលែងមាន នឹងត្រឡប់មកវិញ បើយើងឈប់ចាក់ថ្នាំបង្ការ ។ វាបានកើតឡើងក្នុងផ្នែកខ្លះ



U.S. Department of Health and Human Services
Centers for Disease Control and Prevention

This VIS translation is out of date. When you give your patient this translation, also give them the up-to-date English version of it.
To get both, and to find out what was updated, go to www.immunize.org/vis

**ថ្នាំបង្ការកុមារចំនួនប្រាំ**អាចការពារកូនរបស់អ្នកពីជម្ងឺទាំងប្រាំពីរនេះ ៖

| ថ្នាំបង្ការ | ចំនួនទទួល | អាយុដែលផ្តល់យោបល់ឲ្យទទួល | ព័ត៌មានផ្សេងទៀត |
|---|---|---|---|
| DTaP ( រោគខាន់ស្លាក់ តេតាណូស ជម្ងឺក្អកមាន់ ) | 5 | 2 ខែ 4 ខែ 6 ខែ 15-18 ខែ 4-6 ឆ្នាំ | កុមារខ្លះមិនគួរទទួលថ្នាំបង្ការជម្ងឺក្អកមាន់ទេ ។ កុមារទាំងនេះអាចទទួលថ្នាំបង្ការដែលហៅថា DT ( រោគខាន់ស្លាក់ និងតេតាណូស ) ។ |
| ជំងឺរលាកថ្លើមប្រភេទ B | 3 | កំណើត 1-2 ខែ 6-18 ខែ | |
| រោគខ្វិនឆ្អឹងខ្នង | 4 | 2 ខែ 4 ខែ 6-18 ខែ 4-6 ឆ្នាំ | បរិមាណបន្ថែមនៃថ្នាំបង្ការរោគខ្វិនឆ្អឹងខ្នងអាចត្រូវបានផ្តល់យោបល់ឲ្យទទួលសម្រាប់ការធ្វើដំណើរទៅប្រទេសខ្លះ ។ |
| Hib *( បាក់តេរីដែលបង្កឲ្យរលាកស្រោមខួរ )* | 3 ឬ 4 | 2 ខែ 4 ខែ ( 6 ខែ ) 12-15 ខែ | មានថ្នាំបង្ការ Hib ច្រើនប្រភេទ ។ ដែលមួយក្នុងចំណោមនោះមិនចាំបាច់ទទួលបរិមាណ 6 ខែ ។ |
| PCV13 ( pneumococcal ) | 4 | 2 ខែ 4 ខែ 6 ខែ 12-15 ខែ | កុមារមានអាយុច្រើនមានស្ថានភាពសុខភាពណាមួយក៏អាចត្រូវការទទួលថ្នាំបង្ការនេះ ។ |

អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកអាចផ្តល់ថ្នាំបង្ការទាំងនេះខ្លះជាថ្នាំបង្ការរួមគ្នា - ថ្នាំបង្ការច្រើនចាក់ក្នុងថ្នាំតែមួយ ។ថ្នាំបង្ការរួមគ្នាមានសុវត្ថិភាព និងប្រសិទ្ធិភាពដូចថ្នាំបង្ការមួយៗដែរ និងអាចមានន័យថាចាក់តិចបីដងសម្រាប់កូនអ្នក ។

នៃពិភពលោករួចហើយ ។ **នៅពេលដែលទារកតិចតួចទទួលថ្នាំបង្ការ ទារកច្រើន**ឈឺ ។ ជាធម្មតា ទារកឆ្លងជម្ងឺទាំងនេះពីកុមារ និងមនុស្សពេញវ័យផ្សេងទៀត ដែលមិនដឹងថាពួកគេត្រូវបានឆ្លង ។ ម្តាយ កើតជំ**ងឺរលាកថ្លើមប្រភេទ** B អាចឆ្លងមកកូនរបស់នាងពេលកើត ។ **តេតាណូស**ចូលក្នុងខ្លួនតាមស្នាមមុត ឬរបួស ។ វាមិនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទេ ។

## 2 ក្មេងខ្លះមិនគួរទទួលថ្នាំបង្ការណាមួយទេ

កុមារភាគច្រើនអាចទទួលថ្នាំបង្ការទាំងនេះដោយសុវត្ថិភាព ។ ប៉ុន្តែមានករណីលើកលែងខ្លះ ៖

- កុមារដែលឈឺថ្ងៃដែលកំណត់ទទួលថ្នាំបង្ការអាចត្រូវបានស្នើសុំឲ្យត្រឡប់មកពេលក្រោយ ។
- កុមារទាំងឡាយដែលមានប្រតិកម្មស្ទើរស្លាប់ក្រោយពីទទួលថ្នាំបង្ការ មិនគួរទទួលបរិមាណមួយទៀតនៃថ្នាំបង្ការទេ ។

  កុមារដែលមានប្រតិកម្មធ្ងន់ធ្ងរ ( ស្ទើរស្លាប់ ) ជាមួយសារធាតុ មិនគួរទទួលថ្នាំបង្ការដែលមានសារធាតុនោះទេ ។ ថ្នាំបង្ការទាំងនេះខ្លះមាន neomycin streptomycin yeast lactose sucrose ឬ latex ។

***ប្រាប់គ្រូពេទ្យបើកូនរបស់អ្នកមានប្រតិកម្មធ្ងន់ធ្ងរណាមួយ ឬធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយពីទទួលថ្នាំបង្ការណាមួយ ។***

***និយាយជាមួយគ្រូពេទ្យមុនកូនរបស់អ្នកទទួល****....*

....**ថ្នាំបង្ការ** DTaP បើកូនអ្នកធ្លាប់មានប្រតិកម្មទាំងនេះក្រោយពីបរិមាណពីមុននៃ DTaP ៖

- ជម្ងឺប្រព័ន្ធខួរក្បាល ឬសរសៃប្រសាទក្នុងរយៈពេល 7 ថ្ងៃ
- យំមិនឈប់រយៈពេល 3 ម៉ោង ឬច្រើនជាងនេះ
- ប្រកាច់ ឬសន្លប់
- ក្តៅខ្លួនលើសពី 105°F ។

...**ថ្នាំបង្ការរោគខ្វិនឆ្អឹងខ្នង** បើកូនអ្នកមានប្រតិកម្មធ្ងន់ធ្ងរជាមួយ antibiotics neomycin streptomycin ឬ polymyxin B ។

...**ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ** B បើកូនអ្នកមានប្រតិកម្មធ្ងន់ធ្ងរជាមួយផ្សិតដំបែ ។

...**ថ្នាំបង្ការ** PCV13 បើកូនអ្នកមានប្រតិកម្មធ្ងន់ធ្ងរជាមួយផ្សិតដំបែ ឬធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយពីទទួល DTaP ( ឬថ្នាំបង្ការផ្សេងទៀតដែលមាន diphtheria toxoid ) ឬក្រោយពីទទួល PCV7 ថ្នាំបង្ការ pneumococcal ដំបូង ។

## 3 ហានិភ័យចំនួន ប្រតិកម្មថ្នាំបង្ការ

ថ្នាំបង្ការ ដូចជាថ្នាំដែរ អាចបង្កឲ្យមានប្រតិកម្មអាក្រក់ ។

ប្រតិកម្មថ្នាំបង្ការភាគច្រើនមិនធ្ងន់ ៖

ភាពងាយឈឺ ក្រហម ឬហើមកន្លែងចាក់ ឬក្តៅខ្លួនបន្តិច ។ វាកើតឡើងក្រោយចាក់ភ្លាម និងបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃ ។ វាអាចកើតឡើងប្រហែលថ្នាំបង្ការពាក់កណ្តាលដែលផ្តល់លើថ្នាំបង្ការ ។

**ថ្នាំបង្ការរោគខ្វិនឆ្អឹងខ្នង ជំងឺរលាកថ្លើមប្រភេទ** B និង Hib មានទាក់ទងតែជាមួយប្រតិកម្មស្រាលទាំងនេះទេ ។

ថ្នាំបង្ការកុមារផ្សេងទៀតមានទាក់ទងជាមួយបញ្ហាបន្ថែម ៖

This VIS translation is out of date. When you give your patient this translation, also give them the up-to-date English version of it.
To get both, and to find out what was updated, go to www.immunize.org/vis

**ថ្នាំបង្ការ** DTaP
**បញ្ហាស្រាល ៖** ភាពមួរម៉ៅ (1 ក្នុងចំណោមកុមារ 3 នាក់) ភាពហត់នឿយ ឬមិនឃ្លាន (1 ក្នុងចំណោមកុមារ 10 នាក់) ក្អួត (1 ក្នុងចំណោមកុមារ 50 នាក់) ហើមដៃ ឬជើងទាំងមូលរយៈពេល 1-7 ថ្ងៃ (1 ក្នុងចំណោមកុមារ 30 នាក់) - ជាធម្មតាក្រោយពីលើកទី 4 ឬលើកទី 5 ។

**បញ្ហាមធ្យម ៖** ប្រកាច់ (1 ក្នុងចំណោមកុមារ 14,000 នាក់) យំមិនឈប់រយៈពេល 3 ម៉ោងឬយូរជាងនេះ (1 ក្នុងចំណោមកុមារ 1,000 នាក់) ក្តៅខ្លួនលើសពី 105°F (1 ក្នុងចំណោមកុមារ 16,000 នាក់) ។

**បញ្ហាធ្ងន់ធ្ងរ ៖** ប្រកាច់រយៈពេលយូរ ដំណើរភ្លឹក ស្តឹក ផ្នែកខាងក្រោម និងការខូចខាតខួរក្បាលជាអចិន្ត្រៃយ៍ត្រូវបានរាយការណ៍ក្រោយពីពីទទួលថ្នាំបង្ការ DTaP ។ របាយការណ៍ទាំងនេះគឺក្រមបំផុត ។

**ថ្នាំបង្ការ** Pneumococcal
**បញ្ហាស្រាល ៖** ភាពងងុយគេង ឬមិនឃ្លានបណ្តោះអាសន្ន (1 ក្នុងចំណោមកុមារ 2 ឬ 3 នាក់) ភាពមួរម៉ៅ (8 ក្នុងចំណោមកុមារ 10 នាក់) ។

**បញ្ហាមធ្យម ៖** ក្តៅខ្លួនលើសពី 102.2°F (1 ក្នុងចំណោមកុមារ 20 នាក់)

**បញ្ហាដែលអាចកើតមានក្រោយពីទទួលថ្នាំបង្ការ ៖**
- រយៈពេលសន្លប់ខ្លីៗអាចកើតឡើងក្រោយនិតិវិធីវេជ្ជសាស្ត្រ ដែលរាប់បញ្ចូលទាំងការទទួលថ្នាំបង្ការ ។ ការអង្គុយ ឬស្រមាក 15 នាទី អាចជួយការពារសន្លប់ និងរបួសដែលបណ្តាលពីការដួល ។
- ឈឺស្មារខ្លាំង និងកាត់បន្ថយប្រវែងចលនាដៃត្រង់កន្លែងចាក់ អាចកើតឡើងដោយក្រមបំផុត ក្រោយពីទទួលថ្នាំបង្ការ ។
- ប្រតិកម្មធ្ងន់ធ្ងរពីថ្នាំបង្ការគឺក្រមបំផុត ដែលប៉ាន់ស្មានតិចជាង 1 ក្នុងមួយលានចំនួន ។ បើមានកើតឡើង វាកើតក្នុងរយៈពេលពីរបីនាទីដល់ពីរបីម៉ោង ក្រោយទទួលថ្នាំបង្ការ ។

ខុសពីថ្នាំទាំងឡាយ មានឱកាសតិចណាស់ដែលថ្នាំបង្ការអាចបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរ ឬស្លាប់ ។

សុវត្ថិភាពនៃថ្នាំបង្ការតែងត្រូវបានត្រួតពិនិត្យ ។ ស្រមាប់ព័ត៌មានបន្ថែម ចូលទៅគេហទំព័រ ៖
**www.cdc.gov/vaccinesafety/**

## 4 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ ?

**តើខ្ញុំគួរតែរកមើលអ្វី**
- រកមើលអ្វីដែលធ្វើឲ្យអ្នកព្រួយបារម្ភ ដូចជាសញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ ក្តៅខ្លួនខ្លាំង ឬប្រែប្រួលអាកប្បកិរិយា ។

  សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរអាចរាប់បញ្ចូលទាំងបន្ទាលត្រអាក ហើមមុខនិងក ពិបាកដកដង្ហើម ចង្វាក់បេះដូងលោតញាប់ វិលមុខ និងខ្សោយ ។ ជាធម្មតាវាចាប់ផ្តើមពីរបីនាទីដល់ពីរបីម៉ោង ក្រោយពេលទទួលថ្នាំបង្ការ ។

**តើខ្ញុំគួរធ្វើយ៉ាងណា ?**
- បើអ្នកគិតថាវាជាប្រតិកម្មធ្ងន់ធ្ងរ ឬការសង្គ្រោះបន្ទាន់ផ្សេងទៀតដែលមិនអាចចាំបាន ទូរស័ព្ទទៅ 9-1-1 ឬបញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតបំផុត ។ មិនដូច្នោះ ទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ។,
- ក្រោយមក ប្រតិកម្មគួរតែត្រូវបានរាយការណ៍ទៅប្រព័ន្ធរាយការណ៍ឥទ្ធិពលផ្សេងនៃថ្នាំបង្ការ (VAERS) ។ គ្រូពេទ្យរបស់អ្នកគួរតែដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាខ្លួនឯងតាមរយៈគេហទំព័រ VAERS **www.vaers.hhs.gov** ឬទូរស័ព្ទទៅ **1-800-822-7967** ។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ ។*

## 5 កម្មវិធីសំណងរបួសថ្នាំបង្ការថ្នាក់ជាតិ

កម្មវិធីសំណងរបួសថ្នាំបង្ការថ្នាក់ជាតិ (VICP) គឺកម្មវិធីសហព័ន្ធដែលបានបង្កើតដើម្បីសងអ្នកដែលត្រូវធ្វើឲ្យរបួសដោយថ្នាំបង្ការណាមួយ ។

អ្នកដែលគិតថាពួកគេអាចរងរបួសដោយសារថ្នាំបង្ការ អាចសិក្សាអំពីកម្មវិធី និងបំពេញការទាមទារដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅគេហទំព័រ VICP តាម **www.hrsa.gov/vaccinecompensation** ។ មានពេលកំណត់ដើម្បីដាក់បណ្តឹងទាមទារស្រមាប់សំណង ។

## 6 តើខ្ញុំយល់ដឹងបន្ថែមតាមរបៀបណា ?

- សាកសួរគ្រូពេទ្យអ្នក
- ទូរស័ព្ទទៅក្រសួងសុខាភិបាលតំបន់ ឬរដ្ឋអ្នក
- ទាក់ទងមជ្ឈមណ្ឌលគ្រប់គ្រងជម្ងឺ និងការការពារ (CDC) ៖
  - ទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)**
  - ចូលទៅគេហទំព័ររបស់ CDC **www.cdc.gov/vaccines** ឬ **www.cdc.gov/hepatitis**

Vaccine Information Statement (Interim)
Multi-Vaccine
Cambodian

10/22/2014

42 U.S.C. § 300aa-26

Office Use Only

Translation provided by the California Department of Public Health